**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

SOCIAL PROTECTION IN CAMBODIA

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃកញ្ចប់វិធានការរបស់រាជរដ្ឋាភិបាល (លើកទី១)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ៨ ៨៣១នាក់ នៃរោងចក្រទាំង១៩ នៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃសេចក្តីណែនាំលេខ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតធ្វើការនៅរោងចក្រក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ដោយសារវិបត្តិសេដ្ឋកិច្ចសកល ជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ នាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួនៈ

- ៨១ ០០០រៀល (២០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១៤ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាម៉េរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១៥ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះ ទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រទាំង១៩ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួនទៅរដ្ឋបាលរោងចក្ររបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មករនិយោជិតរោងចក្រដទៃផ្សេងទៀត ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមរួសរាន់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃ ច័ន្ទ ១៤កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

**ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី៣១ខែតុលា ឆ្នាំ២០២៣**

**បញ្ជីឈ្មោះ រោងចក្រ ក្នុងវិស័យកាត់ដេរ**

**ចំនួន ១៩ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល**

| ល.រ | ឈ្មោះរោងចក្រ | រាជធានី ខេត្ត |
|---|---|---|
| វិស័យកាត់ដេរ | | 19 |
| 1 | ក្រុមហ៊ុន ខ្វាន់ទុម ខ្លូស៊ីង (ខេមបូឌា) លីមីតធីត | ភ្នំពេញ |
| 2 | ក្រុមហ៊ុន យីងសិនសេងព្រីនធីង ឯ.ក | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ដាយ៉ាប គ្លូបិលម ខូអិលធីឌី | ភ្នំពេញ |
| 4 | ក្រុមហ៊ុន ហុង វ៉ា (កម្ពុជា) ហ្គាមិន ម៉ាញូហ្វាក់ធីរីង លីមីធីត | ភ្នំពេញ |
| 5 | ក្រុមហ៊ុន អេចខេ ប៊ុលតិច មេនូហ្វេកធើរី ឯ.ក | ភ្នំពេញ |
| 6 | ក្រុមហ៊ុន ញូ វ៉ាយដ៍ (ខេមបូឌា) ហ្គាមេន | ភ្នំពេញ |
| 7 | ក្រុមហ៊ុនឃ្វៃ យ៉ាង ខេមបូឌា ខូអិលធីឌី | កណ្តាល |
| 8 | ក្រុមហ៊ុន ភីភីអិន ភីសយ អឹថយខូអិលធីឌី | កណ្តាល |
| 9 | ក្រុមហ៊ុន តេ យុង (ខេមបូឌា) ខូ អិលធីឌី | កណ្តាល |
| 10 | ក្រុមហ៊ុន ហ្វ៊ូរឈួន ប្រត ហ្វ៊ូតវែរ ឯ.ក | កណ្តាល |
| 11 | ក្រុមហ៊ុន ស៊ូភៀល (ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 12 | ក្រុមហ៊ុន វ៉េត ម៉ាស ហ្គាម៉ិន (ខេមបូឌា) ឯ.ក | កំពង់ស្ពឺ |
| 13 | ក្រុមហ៊ុន ហ្វីតហ្វ៊ូរវើត (ខេមបូឌា) សកខ៍ | កំពង់ស្ពឺ |
| 14 | ក្រុមហ៊ុន ស៊ុយ យ៉ាត អេ (ខេបូឌា)ខូអិលធីឌី | កំពង់ស្ពឺ |
| 15 | ក្រុមហ៊ុន ខេ.វ៉ាយ អដឹសស៊ី ហ្គាម៉ិន ឯ.ក | កំពង់ស្ពឺ |
| 16 | ក្រុមហ៊ុន ឆាមហ្គោ(ខេមបូឌា)ឯ.ក | កំពង់ស្ពឺ |
| 17 | ក្រុមហ៊ុន មេតថេក (ខេបូឌា) ខប លីមីធីត | កំពង់ចាម |
| 18 | ក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត | ព្រៃវែង |
| 19 | ក្រុមហ៊ុន អរិន មេនូហ្វេកធីរីង ( ខ្មែរ ) | ព្រៃវែង |